**សលាកប័ត្រព័ត៌មានៈ** កម្រងឯកសារសិទ្ធិជាមូលដ្ឋានៈ ការចូលជាសមាជិកសហជីព

**សេរីភាពជាមូលដ្ឋានៈ** សេរីភាពខាងការបញ្ចេញមតិ និងការបង្កើតសមាគម

**ទិដ្ឋភាពរួមៈ** សិទ្ធិសេរីភាពខាងការបង្កើតសមាគម ត្រូវបានការពារដោយបទប្បញ្ញត្តិមួយចំនួននៃច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ទោះជាយ៉ាងដូចនេះក្តី ការរំលោភបំពានជាច្រើនលើសេរីភាពខាងការបង្កើតសមាគម ជារឿយៗតែងកើតមានឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") ដែលត្រូវបានមើលឃើញថាជាប្រទេសដ៏គ្រោះថ្នាក់មួយ នៅពេលចូលជាសមាជិកសហជីព។ នៅខែតុលា ឆ្នាំ២០១៣ អង្គការពលកម្មអន្តរជាតិ ("អាយឡូ") បានដាក់ប្រទេសកម្ពុជា ជាប្រទេសមួយក្នុងចំណោមករណីប្រទេសចំនួន ៣ ថាជា ប្រទេសដែលមានគ្រោះថ្នាក់ និងចាំបាច់បំផុតត្រូវដោះស្រាយពាក់ព័ន្ធនឹងសេរីភាពខាងការបង្កើតសមាគម។

**សេចក្តីផ្តើម**

ដោយពិនិត្យមើលទៅលើព្រឹត្តិការណ៍ថ្មីៗនៅកម្ពុជា និងការកើនឡើងនៃការបង្ក្រាបលើសេរីភាពខាងការបង្កើតសមាគម សលាកប័ត្រព័ត៌មាននេះ ធ្វើការត្រួតពិនិត្យទៅលើសិទ្ធិសេរីភាពខាងការបង្កើតសមាគមនៅកម្ពុជា ជាពិសេសនៅក្នុងបរិបទនៃការចូលជាសមាជិកសហជីព។ សេរីភាពខាងការបង្កើតសមាគម ជាសិទ្ធិមូលដ្ឋានរបស់មនុស្ស ដែលមនុស្សគ្រប់រូបមានសិទ្ធិសេរីភាពខាងការបង្កើតសមាគមជាមួយនឹងអ្នកដទៃ ដែលសិទ្ធិនេះរួមបញ្ចូលទាំងសិទ្ធិបង្កើត និងចូលរួមជាមួយនឹងសហជីពនានា ព្រមទាំងចូលរួមជាមួយនឹងអ្នកដទៃដើម្បីស្វែងរក និងលើកតម្កើងបុព្វហេតុ និងផលប្រយោជន៍រួម។ សិទ្ធិនេះក៏រួមបញ្ចូលសិទ្ធិចូលរួម ឬបង្កើតជាផ្លូវការនូវសមាគមទាំងឡាយ។ ទោះជាយ៉ាងនេះក្តី សិទ្ធិសេរីភាពខាងការបង្កើតសមាគម និងបង្កើតសហជីពត្រូវបានប្រឈមយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជា។

សលាកប័ត្រព័ត៌មាននេះត្រូវបានចងក្រងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្ស សម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

**សេរីភាពខាងការបង្កើតសមាគមៈ ច្បាប់ជាតិ និងច្បាប់អន្តរជាតិ**

សិទ្ធិសេរីភាពខាងការបង្កើតសមាគម ត្រូវបានធានា និងការពារដោយច្បាប់ជាតិ។ មាត្រា ៣៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ចែងថា ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិ *"បង្កើតសហជីព និងចូលជាសមាជិកសហជីព"* នៅខណៈដែលមាត្រា ៣៧ ធានាអំពីសិទ្ធិក្នុងការធ្វើកូដកម្ម និងចូលរួមធ្វើបាតុកម្មដោយសន្តិវិធី។ ម្យ៉ាងវិញទៀត មាត្រា ២៦៦ នៃច្បាប់ស្តីពីការងារបញ្ញត្តថា កម្មករ និងនិយោជិតមានសិទ្ធិបង្កើតអង្គការវិជ្ជាជីវៈក្នុងគោលបំណងសម្រាប់តែការសិក្សា លើកតម្កើងផលប្រយោជន៍ និងការការពារសិទ្ធិចំពោះបុគ្គលដែលកំណត់ដោយលក្ខន្តិកៈរបស់អង្គការនោះ។

បន្ថែមលើនេះទៀត មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ បញ្ញត្តថា កម្ពុជាទទួលស្គាល់ និងគោរពសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("ស.ស.ស.ម") និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយដែលទាក់ទងនឹងសិទ្ធិមនុស្ស ហេតុដូច្នេះ ស.ស.ស.ម និង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") ត្រូវបានបញ្ចូលជាច្បាប់ជាតិ។ មាត្រា ២០ នៃ ស.ស.ស.ម ចែងថា *"មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការជួបប្រជុំ និងការបង្កើតសមាគមដោយសន្តិវិធី"* នៅខណៈដែលមាត្រា ២៣ កំណត់ថា *"មនុស្សគ្រប់រូបមានសិទ្ធិបង្កើត និងចូលរួមសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន"*។ មាត្រា ២២ នៃ ក.អ.ស.ព.ន ដែលរដ្ឋាភិបាលបានផ្តល់សច្ចាប័នក្នុងឆ្នាំ១៩៩២ ក៏ចែងផងដែរអំពី

សិទ្ធិសេរីភាពជាសកលក្នុងការបង្កើតសមាគម និងការចូលជាសមាជិកសហជីព។ កិច្ចការពារបន្ថែមទៀតត្រូវបានកំណត់នៅក្នុងអនុសញ្ញារបស់អាយឡូស្តីពីសេរីភាព និងកិច្ចការពារសិទ្ធិក្នុងការបង្កើត ឆ្នាំ១៩៤៨ ដែលជាអនុសញ្ញាមួយក្នុងចំណោមអនុសញ្ញាជាមូលដ្ឋានសំខាន់ៗទាំង ៨ របស់អាយឡូ ហើយដែលរដ្ឋាភិបាលបានផ្តល់សច្ចាប័នក្នុងឆ្នាំ១៩៩៩។ នៅពេលរដ្ឋាភិបាលបានផ្តល់សច្ចាប័នហើយនោះ អនុសញ្ញាអាយឡូទាំងនោះនឹងបង្កើតជាកាតព្វកិច្ចតាមផ្លូវច្បាប់ដល់រដ្ឋាភិបាល។

ជាចុងក្រោយ សេចក្តីព្រាងច្បាប់ស្តីពីសហជីព ដែលរដ្ឋាភិបាលបានបញ្ចេញកាលពីឆ្នាំ២០១១ ប៉ុន្តែត្រូវបានផ្អាកទៅវិញ បន្ទាប់ពីក្រុមអង្គការសង្គមស៊ីវិល និងសហជីព បានលើកឡើងពីក្តីបារម្ភទាក់ទិននឹងបទប្បញ្ញត្តិជាក់លាក់មួយចំនួននៅក្នុងសេចក្តីព្រាងច្បាប់នោះ រួមទាំងក្តីបារម្ភដែលថា ច្បាប់នេះនឹងធ្វើឲ្យសហជីពកាន់តែងាយរងគ្រោះជាខ្លាំងចំពោះករណីរំលាយ និងលុបចេញពីបញ្ជី ហើយក៏បារម្ភទៀតថា ច្បាប់នេះនឹងបង្កើតឲ្យមានលក្ខខណ្ឌតម្រូវជាបន្ទុកបន្ថែម និងមានការរើសអើង សម្រាប់បុគ្គលទាំងឡាយណា ដែលមានបំណងស្វែងរកតួនាទីជាមេដឹកនាំសហជីព ព្រមទាំងថា ច្បាប់នេះនឹងធ្វើឲ្យរដ្ឋាភិបាលរឹតតែងាយស្រួលជុំវិញការធ្វើសេចក្តីសម្រេចចិត្តលើផ្នែកទាំងអស់នេះក្នុងចំណោមកត្តាផ្សេងៗទៀតជាច្រើន។ ទោះជាយ៉ាងណាក្តី សេចក្តីព្រាងច្បាប់នេះហាក់ដូចជាត្រូវបានដាក់ឲ្យគណៈរដ្ឋមន្ត្រីធ្វើការពិនិត្យកាលពីចុងឆ្នាំ២០១៣ និងប្រហែលជានឹងត្រូវរដ្ឋសភាអនុម័តនៅដើមឆ្នាំ២០១៤នេះ។

## សិទ្ធិសេរីភាពខាងការបង្កើតសមាគម និងការចូលជាសមាជិកសហជីពនៅកម្ពុជា

ស្ថានភាពនៃសេរីភាពខាងការបង្កើតសមាគមនៅកម្ពុជាកំពុងតែប្រឈមខ្លាំង។ ជាពិសេស វិស័យកាត់ដេរ ដែលជាប្រភពចំណូលតាមរយៈការនាំចេញដ៏ធំបំផុតរបស់កម្ពុជា ត្រូវបានញាំញីដោយការមិនគោរព និងការរំលោភបំពានជាច្រើនលើសិទ្ធិសេរីភាពខាងការបង្កើតសមាគម។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាត្រូវបានគេមើលឃើញថា ជាប្រទេសដែលគ្រោះថ្នាក់ក្នុងការធ្វើជាអ្នកដឹកនាំសហជីព ហើយជាញឹកញាប់ សមាជិកសហជីពតែងតែប្រឈមនឹងហិង្សា និងការចាប់ខ្លួនជុំវិញសកម្មភាពរបស់ខ្លួននៅក្នុងបរិយាកាសនិទណ្ឌភាព។

កូដកម្ម និងបាតុកម្មនានា ដែលដឹកនាំដោយសហជីព ជារឿយៗត្រូវបានបំបែកយ៉ាងហិង្សាដោយអាជ្ញាធរ ហើយដែលមានការប្រើប្រាស់គ្រាប់សេរដែលបណ្តាលឲ្យគ្រោះថ្នាក់ដល់អាយុជីវិតកើតឡើងច្រើនជាទូទៅ។ បន្ថែមលើនេះទៀត កម្មករដែលជាសមាជិកសហជីព ក៏ដូចជា អ្នកតំណាង និងមេដឹកនាំសហជីព រមែងតែងតែត្រូវបានបណ្តេញចេញពីការងារដែលជាលទ្ធផលនៃសកម្មភាពសហជីពរបស់ខ្លួន។ នៅដើមខែមករា ឆ្នាំ២០១៤ យ៉ាងហោចណាស់មានសមាជិកចំនួន ៥០ មកពីសហព័ន្ធសហជីពចលនាកម្មករ និងសម្ព័ន្ធសហជីពកម្ពុជា ត្រូវបានបណ្តេញចេញពីរោងចក្រមួយចំនួនដែលស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេសម៉ាញ៉ាតាន់ក្នុងខេត្តស្វាយរៀង ដោយចោទប្រកាន់ពីការចូលរួមធ្វើកូដកម្មនៅក្នុងខែធ្នូ ឆ្នាំ២០១៣។ សមាជិកសហជីពក៏ប្រឈមនឹងការគំរាមកំហែងតាមផ្លូវច្បាប់ ដោយសារតែភាពសកម្មរបស់ខ្លួនផងដែរ។ បច្ចុប្បន្ននេះ រោងចក្រកាត់ដេរមួយចំនួនកំពុងតែស្វែងរកវិធានការច្បាប់ប្រឆាំងនឹងកម្មករដែលចូលរួមក្នុងការធ្វើកូដកម្ម ហើយរដ្ឋាភិបាលបានគំរាមសហជីពថា ប្រសិនជាសហជីពណានៅតែបន្តធ្វើកូដកម្ម សហជីពនោះនឹងត្រូវបានព្យួរ ឬលុបចោលអាជ្ញាប័ណ្ណ ស្របពេលដែលមេដឹកនាំសហជីពក៏អាចនឹងប្រឈមនឹងបណ្តឹងនានាផងដែរ។

ក្តីបារម្ភចម្បង គឺឧប្បត្តិហេតុដែលមេដឹកនាំសហជីពមួយចំនួនទទួលការគំរាមសម្លាប់ ឬត្រូវបានសម្លាប់ ដោយសារតែលទ្ធផលនៃសកម្មភាពសហជីពរបស់ខ្លួន។ នៅក្នុងរយៈពេល ១០ ឆ្នាំកន្លងទៅនេះ មេដឹកនាំសហជីពចំនួន ៣ នាក់

រួមមាន លោក ជា វិជ្ជា លោក រស់ សុវណ្ណារ៉េត និងលោក ហ៊ី វុទ្ធី ត្រូវបានគេធ្វើឃាតនៅប្រទេសកម្ពុជា។ ករណីដែលគួរឲ្យកត់សម្គាល់បំផុតនោះគឺ ការសម្លាប់លោក ជា វិជ្ជា ដែលជាមេដឹកនាំសហជីពសេរីកម្មករនៅព្រះរាជាណាចក្រកម្ពុជា ដែលលោកត្រូវបានឃាតករបាញ់សម្លាប់នៅកណ្ដាលថ្ងៃក្នុងរាជធានីភ្នំពេញកាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០០៤។ ទោះបីជានគរបាលបានចាប់ខ្លួនបុរស ២ នាក់ គឺលោក បិន សំណាង និងលោក សុខ សំអឿន ហើយបានចោទប្រកាន់បុរសទាំង ២ នាក់នេះពីបទមនុស្សឃាតក្ដី ក្រោយមកភ្លាមៗនោះ ការចាប់ខ្លួននេះបានបង្ហាញយ៉ាងច្បាស់ថា អ្នកទាំង ២ នាក់នេះគឺជាឃាតករសប្បនិម្មិត ដើម្បីបិទបាំងឃាតករពិតតែប៉ុណ្ណោះ។ ជនជាប់ចោទទាំង ២ នាក់នេះត្រូវបានតុលាការលើកលែងការចោទប្រកាន់កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ ហើយឃាតករពិតសម្លាប់លោក ជា វិជ្ជា នៅតែមិនទាន់រកឃើញនៅឡើយ។ ហេតុការណ៍ថ្មីៗកាលពីខែវិច្ឆិកា ឆ្នាំ២០១៣ លោក អាត់ ធន់ ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ត្រូវបានរាយការណ៍ថា បានទទួលការហៅទូរសព្ទរបស់ជនអនាមិកជាច្រើនដង ដែលនៅក្នុងអំឡុងពេលលើកទូរសព្ទនោះ លោក អាត់ ធន់ និងមន្ត្រីសហជីពមួយចំនួនទៀតត្រូវបានគំរាមសម្លាប់។

**សេចក្ដីសន្និដ្ឋាន**

ការខកខានក្នុងការស៊ើបអង្កេតលើការករណីឃាតកម្ម និងការគំរាមកំហែងសម្លាប់ជាច្រើនប្រឆាំងនឹងមេដឹកនាំសហជីពមួយចំនួន និងការខកខានក្នុងការនាំជនល្មើសពិតប្រាកដមកផ្ដន្ទាទោស បានក្លាយជាវប្បធម៌និទណ្ឌភាពនៅកម្ពុជា។ បញ្ហានេះ រួមជាមួយនឹងការរឹតត្បិតសិទ្ធិសេរីភាពរបស់សមាជិកសហជីពជាបន្តបន្ទាប់ បានបណ្ដាលបំពានដល់សេរីភាពខាងការបង្កើតសមាគមយ៉ាងទូលំទូលាយ។ រដ្ឋាភិបាលកម្ពុជា ត្រូវតែទទួលស្គាល់ និងធានាសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងការចូលជាសមាជិកសហជីពនៅកម្ពុជា។ ម្យ៉ាងវិញទៀត ម.ស.ម.ក សូមជំរុញឲ្យរដ្ឋាភិបាលត្រូវធានាឲ្យមានការពិគ្រោះពិភាក្សាឲ្យបានពេញលេញជាមួយនឹងអង្គការសង្គមស៊ីវិល សហជីព និងកម្មករ ទាក់ទិននឹងសេចក្ដីព្រាងច្បាប់ស្ដីពីសហជីព ព្រមទាំងត្រូវធានាថា ច្បាប់បែបនេះនឹងត្រូវឆ្លុះបញ្ចាំងពីគោលការណ៍សិទ្ធិមនុស្សនានា។

**សម្រាប់ព័ត៌មានលម្អិត សូមទាក់ទងលោក ឌុច ពិសិដ្ឋ អ្នកសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្ស តាមរយៈទូរសព្ទ៖ +៨៥៥ (០) ១២ ៧១ ២៣ ៧១ ឬតាមរយៈអ៊ីម៉ែល៖ duchpiseth@cchrcambodia.org ឬ លោកស្រី ហ្សូលីយ៉េត រ៉ូស្សេឡូត តាមរយៈទូរសព្ទ៖ +៨៥៥ (០) ១៥ ៣៥ ០៦ ២០ ឬតាមរយៈអ៊ីម៉ែល៖** julietterousselot@cchrcambodia.org ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

BY NC SA